អាលម៉ា ១៧–២២
ថ្ងៃទី ២២–២៨ ខែ មិថុនា

# តើខ្ញុំអាចអនុវត្តសេចក្ដីជំនឿភ្លាមៗដោយរបៀបណា ?

សកម្មភាពដ៏ស្មោះត្រង់ និងភ្លាមៗរបស់អ័ប៊ីសនៅក្នុងព្រះគម្ពីរមរមន បង្ហាញពីរបៀបដែលសេចក្ដីជំនឿជួយនាំអ្នកដទៃទៀតឲ្យមកកាន់ព្រះគ្រីស្ទ ។ សូមពិចារណាពីរបៀបដែលនាង « បានប្រែចិត្តជឿដល់ព្រះអម្ចាស់ » ទាំងស្រុង ( អាលម៉ា ១៩:១៦ ) ។

## ការពិភាក្សា

តើអ្នកអាចពង្រឹងសេចក្ដីជំនឿរបស់អ្នកលើព្រះដោយរបៀបណា ដើម្បីឲ្យអ្នក ហើយប្រហែលជាអ្នកដទៃផងនឹងទទួលអារម្មណ៍នៃអំណាចដើម្បីអនុវត្តភ្លាមៗ និងពេញលេញទៅលើព្រះឆន្ទៈរបស់ព្រះ ?

ចេញរូបភាពដោយ អែនឌ្រូ ប៊ិសលី រូបភាពផ្ទៃខាងក្រោយមកពី GETTY IMAGES



## នាងបានដឹងពីវា

សេចក្ដីជំនឿរបស់អ័ប៊ីសគឺខ្លាំងណាស់ រហូតដល់ពេលដែលនាងបានឃើញអ្នកផ្ទះរបស់ឡាម៉ូណៃបានដួលចុះទៅលើដី នាង « ដឹងថា នេះហើយជាព្រះចេស្ដានៃព្រះ » ( អាលម៉ា ១៩:១៧ ) ។ តើអ្នកអាចស្ថាបនាសេចក្ដីជំនឿរបស់អ្នកដើម្បីដឹងពីព្រះចេស្ដានៃព្រះ ដូចជាអ័ប៊ីសបានដឹងដោយរបៀបណា ?



## នាងបានរត់ទៅ

ពេលដែលអ័ប៊ីសបានដឹងពីព្រះចេស្ដានៃព្រះ នាង « បានរត់ពីផ្ទះមួយទៅផ្ទះមួយ » ហើយបានប្រាប់ប្រជាជនឲ្យមកមើលអព្ភូតហេតុនោះ ( អាលម៉ា ១៩:១៧ ) ។ សេចក្ដីជំនឿរបស់នាងបានផ្ដល់អំណាចដល់នាងដើម្បីអនុវត្តភ្លាមៗ ។ តើមានចំណុចណាមួយនៃដំណឹងល្អដែលអ្នកបានដើរ ជំនួសឲ្យរត់វិញ ក្នុងការអនុវត្តតាមព្រះឆន្ទៈរបស់ព្រះដោយសេចក្ដីជំនឿនោះ ?



## នាងបានកាន់ដៃនាំអ្នកដទៃទៀតឲ្យមក

អ័ប៊ីស « ចាប់ព្រះហស្តនៃព្រះអគ្គមហេសី » ដោយសេចក្ដីជំនឿថាវានឹងធ្វើឲ្យព្រះអគ្គមហេសីឈរឡើង ( អាលម៉ា ១៩:២៩ ) ។ នាងបានធ្វើនូវអ្វីដែលហាក់ដូចជាពុំអាចទៅរួច ដោយសារសេចក្ដីជំនឿរបស់នាងលើព្រះ ។ តើអ្នកអាចពង្រឹងសេចក្ដីជំនឿរបស់អ្នកលើព្រះ ហើយសម្រេចនូវអ្វីដែលមិនអាចទៅរួចនៅក្នុងជីវិតអ្នកដោយរបៀបណា ?